មជ្ឈមណ្ឌលឯកសារកម្ពុជា




Documentation Center of Cambodia
Searching for the Truth ស្វែងរកការពិត ដើម្បីការចងចាំនិងយុត្តិធម៌

DC-Cam ◆ 66 Preah Sihanouk Blvd. ◆ P.O.Box 1110 ◆ Phnom Penh ◆ Cambodia
Tel: (855-23) 211-875 ◆ Fax: (855-23) 210-358 ◆ dccam@online.com.kh ◆ www.dccam.org

# ធម្មយាត្រារបស់ដូនជីៈ ដំណើរសន្តិភាពឆ្ពោះទៅរកការផ្សះផ្សាជាតិ

## ទិចារណកថរបស់ឧកញ៉ា មហាឧបាសិក ញ៉ឹក ប៊ុនថា

*ប្រែសម្រួលដោយៈ សើ សាយ្យាណា និង ព្រំ ផល្លា*

រយៈពេលជាច្រើនឆ្នាំ បន្ទាប់ពីរបបខ្មែរក្រហមត្រូវបានបណ្តេញចេញពីអំណាច រដ្ឋាភិបាលបន្ទាប់បានផ្តោតការយកចិត្តទុកដាក់តិចតួចចំពោះការផ្សះផ្សាជាតិដោយសារតែនៅមានការប្រយុទ្ធគ្នារវាងកងទ័ពរដ្ឋាភិបាលនិងកម្លាំងខ្មែរក្រហមដែលនៅសេសសល់តាមបណ្តោយព្រំដែនភាគខាងលិចប្រទេសកម្ពុជានៅឡើយ ។ ការខិតខំប្រឹងប្រែងរបស់ពុទ្ធសាសនិកជនក្រោយរបបខ្មែរក្រហមគឺមិនអាចធ្វើទៅបានប្រសិនបើគ្មានសាសនាណែនាំផ្លូវឆ្ពោះទៅរកការរំងាប់អារម្មណ៍ ។ បន្ទាប់ពីកិច្ចព្រមព្រៀងបញ្ចប់សង្គ្រាមនៅឆ្នាំ១៩៩១ ពេលនោះអង្គការសង្គមស៊ីវិលត្រូវបានបង្កើតឡើងជាបន្តបន្ទាប់នៅក្នុងប្រទេសកម្ពុជា ហើយជំហានដំបូងក្នុងការផ្តួចផ្តើមគំនិតដើម្បីផ្សះផ្សាជាតិបានកើតមានឡើងប៉ុន្តែស្ថាប័នសាសនានៅតែជាមគ្គុទេសក៍ដ៏សមស្របសម្រាប់ដំណើរការផ្សះផ្សា ការអភិវឌ្ឍន៍ និងការកសាងសន្តិភាពក្នុងសង្គមកម្ពុជាឆ្ពោះទៅរកការបម្រើនលូតលាស់ឡើងវិញ ។ ការចរចាររវាងរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិបានចាប់ផ្តើមនៅឆ្នាំ១៩៩៧ ដោយបានសម្រេចបង្កើតឲ្យមានតុលាការចម្រុះរវាងកម្ពុជានិងអង្គការសហប្រជាជាតិ ដើម្បីនាំយកអតីតមេដឹកនាំខ្មែរក្រហមមកកាត់ទោសចំពោះអំពើដែលខ្លួនបានប្រព្រឹត្តលើជនរងគ្រោះនៅក្នុងរបបវាលពិឃាត ។ ការឆ្លើយតបពីគ្រប់មជ្ឈដ្ឋានមកវិញចំពោះដំណើរការរបស់តុលាការនេះមានលក្ខណៈផ្សេងៗគ្នា ។ តាមរយៈការបង្កើតធម្មយាត្រាដែលមានការចូលរួមពីសំណាក់ដូនជីដើម្បីសូមឲ្យមានការរួមគ្នាឡើងវិញដោយដើរតាមគន្លងព្រះពុទ្ធជាម្ចាស់ ដែលបានអប់រំជនគ្រប់រូបឲ្យប្រព្រឹត្តអំពើល្អ គឺជាផ្នែកមួយក្នុងការព្យាបាលរបួសសង្គម ។

អំពើបាបមានច្រើនណាស់នៅក្នុងសង្គម ព្រះអង្គទ្រង់សម្តែងធម៌ជាច្រើនទាក់ទងនឹងបញ្ហានេះ តែសូមលើកខ្លះៗមកឆ្លុះបញ្ចាំងទាំងអស់គ្នាឲ្យឃើញថាអ្វីជាអំពើអាក្រក់ ជាអំពើសៅហ្មង ដែលហៅថាជាអកុសលកម្ម ឬ អករណីយកិច្ច ។ អករណីយកិច្ច គឺជាកិច្ចដែលមិនគួរធ្វើ ឬជាធម៌ដែលមិនត្រូវ





ធ្វើដោយដាច់ខាត ជាអំពើអសីលធម៌ អ្នកប្រាជ្ញទាំងឡាយតែងតិះដៀល ។ អ្នកកសាងនូវអំពើបាបទាំងនេះរមែងសៅហ្មងខ្លួនឯង តែងក្តៅក្រហាយខ្លួនឯង ត្រូវទទួលទុក្ខទោសពីផលអាក្រក់ដោយខ្លួនឯងក្នុងចិត្តបច្ចុប្បន្ននេះ ព្រោះអំពើទុច្ចរិត ទាំងតាមផ្លូវកាយវាចាចិត្តនេះត្រូវទទួលទោសធ្ងន់ទៅតាមអំពើ សកម្មភាពអាក្រក់ខុសនឹងច្បាប់ ត្រូវរាជការចាប់យកទៅផ្តន្ទាទោស ត្រូវគេរិះគន់ ដៀលត្មះវិនាសអន្តរាយទ្រព្យសម្បត្តិ និងកិត្តិយស ។ បុគ្គលនោះក្លាយជាមនុស្សបាប ដែលគេហៅថាមនុស្សទុច្ចរិត មនុស្សចិត្តអាក្រក់ ជាឃាតករ ជាចោរ ជាមនុស្សឆបោក មនុស្សខ្វះសតិសម្បជញ្ញៈ ជាមនុស្សឆ្កួតស្រា ឆ្កួតស្រី ឆ្កួតល្បែងពាលាជាដើម ។ អ្នកធ្វើអំពើបាបក្នុងបច្ចុប្បន្ននេះ ក៏ត្រូវទទួលផលអាក្រក់ក្នុងបច្ចុប្បន្ន ទោះបីអ្នកធ្វើអំពើបាបក្នុងទីស្ងាត់កំបាំង សម្គាល់ថាឥតនរណាដឹងក៏ដោយ ក៏តែងតែបណ្តុះចិត្តបាបឲ្យរីករាយក្នុងការប្រព្រឹត្តអំពើបាបថែមទៀត ។ ពេលដែលមិនទាន់ឲ្យផល វាជាគ្រោះថ្នាក់យ៉ាងក្រៃលែង ព្រោះស្មានថាឥតនរណាដឹង ។ ទោះបីពេលនោះមិនទាន់មានអ្នកណាដឹងក៏ពិតមែនតែខ្លួនឯងជាសាក្សីដ៏ពិតប្រាកដចំពោះអំពើបាបដែលខ្លួនឯងបានប្រព្រឹត្តនោះ ។ វាច្បាស់ណាស់ថាអំពើបាបទាំងនេះនឹងជះឥទ្ធិពលអាក្រក់ដល់អ្នកនោះនៅថ្ងៃណាមួយមិនខាន ។ ពេលប្រព្រឹត្តអំពើបាបវាមិនសម្រេចថាអ្នកដទៃដឹងឬមិនដឹងនោះទេ តែផ្ទុយទៅវិញសម្រេចត្រង់ខ្លួនឯងអ្នកធ្វើបាប ហើយអំពើបាបនោះនឹងឲ្យផលជាទុក្ខដល់ខ្លួន ដែលសមដូចពុទ្ធវចនៈសម្តែងថា “ទុក្ខោ បាបស្ស ឧច្ចយោ”



ដែលមានន័យថា ការសន្សំបាប រមែងបាននូវសេចក្តីទុក្ខ ។ អ្នកធ្វើបាប ពុំមែនទទួលផលតែបច្ចុប្បន្ន នេះទេ ប៉ុន្តែអ្នកនោះឯងនឹងត្រូវទទួលផលអាក្រក់នាពេលអនាគត ឬអនាគតជាតិទៀត ។ ពូជអាក្រក់ ដែលសាបព្រោះនាពេលបច្ចុប្បន្នកាលនឹងបន្តទៅអនាគត ។ លោកនេះបន្តភ្ជាប់ទៅបរលោកទៀត វៀរលែងតែអ្នកធ្វើបាបនោះរលត់នូវអកុសលធម៌ដែលអប់រំចិត្តឲ្យសម្រេចបាននូវមគ្គផលដល់និព្វាន ទើបអំពើបាបមិនមានក្នុងជាតិខាងមុខ ។ បើអកុសលធម៌នៅតែមានក្នុងចិត្តនៃអ្នកធ្វើបាប អំពើបាប នោះនឹងនៅតែបន្តឲ្យផលអាក្រក់ទៅទៀត ព្រោះកម្មបច្ចុប្បន្នជាបុព្វហេតុនៃអំពើបាបនាពេលអនាគត ឯកម្មផលអតីត ជាហេតុផលនៃកម្មផលបច្ចុប្បន្ន ។ បណ្ឌិតគួរវៀរចាកបាបឲ្យជ្រះស្អាត ដូចជាមនុស្ស ដែលចង់រស់ គួរវៀរចាកថ្នាំពិសឲ្យបាន ដោយរក្សាខ្លួនជាអ្នកខ្លាចបាប ខ្មាសបាប អ្នកមានសីលទាន ភាវនា មានសេចក្តីព្យាយាម មានខន្តី សេចក្តីអត់ធន់ ប្រុងប្រយ័ត្នប្រកបដោយសតិសម្បជញ្ញៈ សព្វកាល ។ ពេលវេលាកន្លងទៅគ្រប់វិនាទី ក៏បាននាំយកនូវអាយុជីវិតយើងទៅជាមួយដែរ ដូច្នេះ មិនត្រូវប្រមាថបណ្តែតបណ្តោយឲ្យអកុសលធម៌ហូរចូលក្នុងសន្តានចិត្តដោយខ្វះស្មារតី ក្លាយជាមនុស្ស ដែលខ្វះគុណធម៌ ជាមនុស្សមានទោសជាប់ខ្លួន ជាមនុស្សដែលសង្គមស្អប់ខ្ពើម ជាមនុស្សបង្កទុក្ខភ័យ និងវិនាសអន្តរាយដល់ខ្លួនឯង និងសង្គមជាតិឡើយ ។ អំពើបាប ព្រះសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់ត្រាស់ ដឹងច្បាស់ណាស់ថា អ្នកប្រព្រឹត្តអំពើបាបទាំងពួង នាំឲ្យទទួលទុក្ខទោសច្រើនប្រការទាំងក្នុងបច្ចុប្បន្ននិង អនាគត ត្រូវធ្លាក់អបាយភូមិ ទើបព្រះអង្គសម្តែងប្រាប់ដោយព្រះទ័យមេត្តាអនុគ្រោះដល់សត្វលោក ហាមមិនឲ្យធ្វើអំពើបាបផ្សេងៗ ព្រោះអ្នកណាក៏ខ្លាចទុក្ខភ័យ គ្រោះថ្នាក់ ឧបសគ្គ រឿងរ៉ាវស្មុគស្មាញ លំបាកទាំងផ្លូវកាយនិងផ្លូវចិត្ត ព្រមទាំងខ្លាចសេចក្តីអន្តរាយព្រាត់ប្រាសដោយប្រការផ្សេងៗដែរ ។ ការគេចមិនផុតអំពីអំពើអន្តរាយព្រាត់ប្រាសដោយប្រកាផ្សេងៗ នោះគឺដោយសារតែការមិនដឹង ហេតុដែលនាំឲ្យជួប ម្ល៉ោះហើយចេះតែប្រព្រឹត្តទៅ ដោយអកុសលធម៌គ្របសង្កត់ មានលោភៈ ទោសៈ មោហៈ ទិដ្ឋិ មានៈ ឥស្សា មច្ឆរិយៈ ។

ពាក្យដែលទ្រង់ទូន្មានមិនឲ្យធ្វើបាបនេះ មានសារសំខាន់ណាស់ ។ ទ្រង់សម្តែងថា សត្វលោក កម្មណា តែងទទួលផលកម្មដែលបានសាងនោះ និងជាហេតុនាំអបាយដល់ទុគ្គតិទៀត ។ សូមកុំធ្វើអំពើ បាបទាំងឡាយ ទោះបាបនោះតូចក្តីធំក្តី សូមរក្សាខ្លួនក្នុងកុសលធម៌ មានសីលសមាធិវិបស្សនា ។ ទន្ទឹមនេះ អ្នកទាំងពួងត្រូវមានធម៌ខន្តី និងសេចក្តីព្យាយាមទប់ស្កាត់នូវអំពើបាបទាំងឡាយ ដូចពុទ្ធភាសិត សម្តែងថា “ខន្តិ នីរស្ស លង្ការោ ខន្តិតបោបស្សិនោ ខន្តិពលំវយតីនំ ខន្តិហិត សុខាវហា” ។ នេះមាន





ន័យថា ខន្តីជាគ្រឿងអលង្ការរបស់អ្នកប្រាជ្ញ ខន្តីជាគ្រឿងដុតនៃបាបរបស់អ្នកតបធម៌ ខន្តីជាកម្លាំង របស់អ្នកប្រព្រឹត្តធម៌ ខន្តីជាគុណជាតិនាំមកនូវប្រយោជន៍ និងសេចក្តីសុខ ។ ខន្តីនិងសេចក្តីអត់ធន់ មានអំណាចដុតបំផ្លាញបាបធម៌ទាំងឡាយ មានទោសៈ សេចក្តីប្រទូស្ត, លោភៈ សេចក្តីជាប់ជំពាក់ លោភលន់ហួសហេតុ, មោហៈ សេចក្តីវង្វេងមិនដឹងការពិតប្រព្រឹត្តខុស, កោធៈ សេចក្តីក្រោធខឹងគុំកួន, ព្យាបាទៈ សេចក្តីបំផ្លាញឲ្យគេវិនាស, វិហឹសា សេចក្តីបៀតបៀនរំលោភបំពាន, អរតិ សេចក្តីច្រណែន ឈ្នានីស, បដិឃៈ សេចក្តីថ្នាំងថ្នាក់ចិត្ត, កាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិតជាដើម ។ អ្នកមានខន្តី ដោះស្រាយបញ្ហាអ្វីៗដោយសន្តិវិធី និងត្រជាក់ចិត្ត ដោយស្គាល់ហេតុផលច្បាស់លាស់ដែលជាកត្តា នាំឲ្យមានជោគជ័យរាល់ការងារក្នុងជីវិត ។

## អ្នកណាអ្នកធ្វើឲ្យយើងអាក្រក់?

គឺចិត្តអាក្រក់ ចិត្តបាប វាចាអាក្រក់ និងកាយអាក្រក់ ប្រព្រឹត្តអំពើទុច្ចរិតផ្សេងៗនិងការយល់ ខុសរបស់ខ្លួនយើងផ្ទាល់នេះឯង ដែលធ្វើឲ្យខ្លួនយើងក្លាយជាមនុស្សអាក្រក់ មនុស្សទុច្ចរិតជាមនុស្ស ឃោរឃៅ ជាមនុស្សអសីលធម៌ ជាមនុស្សមានទោស ជាមនុស្សដែលគេមិនពេញចិត្ត ។ ជនដែល មិនបានជម្រះចិត្តឲ្យស្អាតបរិសុទ្ធតាមធម៌ព្រះពុទ្ធ ហើយបណ្តោយឲ្យប្រឡាក់នូវកិលេសធម៌ ប្រព្រឹត្ត នូវអំពើអាក្រក់ទាំងឡាយ ទោះក្នុងរូបភាពណាក៏ដោយ ក៏អ្នកនោះឯងត្រូវទទួលផលដែលខ្លួនបាន សាបព្រោះនោះ គ្មានអ្នកណាទទួលជំនួសបានឡើយ ។ ជាច្បាប់ធម្មជាតិ លទ្ធផលនៃកម្មរបស់ជននោះ ត្រូវទទួលទុក្ខទោសទាំងបច្ចុប្បន្ននិងអនាគតជាតិ សមដូចពុទ្ធវចនៈសម្តែងថា “បុគ្គលល្ងង់ខ្លៅមានខ្លួន ឯងជាសត្រូវ” ។ យើងតែងនិយាយថា គេកាត់ទោសជននេះ ជននោះ មានទោសស្រាល កណ្តាល ធ្ងន់ យ៉ាងនេះយ៉ាងនោះ តែទោសទាំងនោះគឺអ្នកមានទោសជាអ្នកដាក់ទោសដោយខ្លួនឯង បើខ្លួនមិន ធ្វើខុស ក៏គេមិនដាក់ទោសដែរ បើទោះជាគ្មានអ្នកណាកាត់ទោស ក៏អំពើបាបកម្មដែលខ្លួនកសាងនោះ ជាអ្នកកាត់ទោសឲ្យជននោះ ទាំងពុទ្ធចក្រ ទាំងអាណាចក្រ ។ នេះជាច្បាប់កម្មផល ។

ហេតុអ្វីបានជាពិភពលោកយើងសព្វថ្ងៃនេះត្រូវប្រឈមមុខនឹងសង្គ្រាម និងអាវុធបំផ្លាញលោក និងអំពើហិង្សារំលោភបំពាន ពីរូបភាពតូចដល់ធំ និងភេរវកម្មតូចធំដូចជាការវាយប្រហារអគារ ពាណិជ្ជកម្មពិភពលោក កាលពីថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០១ នៅទីក្រុងញូវយ៉ក ។ ការកម្ទេចពុទ្ធ បដិមាបុរាណ នៅបាមីយ៉ាន ក្នុងប្រទេសអាហ្គានីស្ថាន ដោយឥតគិតកោតក្រែងជាដើម នេះគឺមកពីចិត្ត បុគ្គលប្រឡាក់ដោយកិលេសធម៌ ជាធម៌អកុសល ។ បុគ្គលនោះពុំបានអប់រំចិត្តក្នុងកុសលធម៌ដែលជា

អំពើទាបថោកនិងគួរឲ្យត្មះតិះដៀល ។ ចិត្តដែលមិនស្អាត ប្រឡាក់ដោយលោភៈ ទោសៈ មោហៈ ទិដ្ឋិមានះ ឥស្សាមទៈ ព្យាបាទៈ ឧបនាហៈ អហិរិកៈ មនោតប្បៈជាដើម នេះកើតមានចំពោះបុគ្គលណាហើយ មិនថាអ្នកបួស អ្នកគ្រប់គ្រងផ្ទះ មិនថាស្ដេច មន្ត្រី អ្នកធំ អ្នកតូចណាទេ តែងនាំចិត្តនោះឲ្យក្ដៅក្រហាយ បាត់ស្មារតី បាត់ការប្រុងប្រយ័ត្ន ដែលបណ្ដោយខ្លួនឲ្យទៅតាមទំនើងចិត្តខុស និងធ្វើឲ្យវិនាសអន្តរាយដល់ខ្លួនឯងនិងអ្នកដទៃ ។ ឧទាហរណ៍ យោងតាមប្រវត្តិសាស្ត្រពិភពលោក ប្រទេសមួយចំនួនត្រូវភ្លើងសង្គ្រាមឆាបឆេះ មានការកាប់សម្លាប់ រំលោភបំពានពីប្រទេសមួយទៅប្រទេសមួយ មានប្រទេសខ្លះឈ្លោះដណ្ដើមអំណាចតែក្នុងប្រទេសខ្លួន ។ ក្នុងន័យនេះដែរ ប្រទេសកម្ពុជាក៏បានទទួលរងទុក្ខលំបាក ដោយសង្គ្រាមនិងការសម្លាប់រង្គាលនៅក្រោមរបប ប៉ុល ពត រយៈពេល៣ឆ្នាំ ៨ខែ ២០ថ្ងៃ ។ អ្នកដឹកនាំរបបនេះ ពេញពោរទៅដោយចិត្តអាក្រក់ ប្រឡាក់ដោយកិលេសធម៌ដែលបានលើកមកហើយ នាំឲ្យប្រព្រឹត្តសកម្មភាព ទាំងតាមផ្លូវកាយនិងវាចា ប្រកបដោយអកុសលធម៌ ។ អ្នកដឹកនាំទាំងនោះបង្កឲ្យមានការកាប់សម្លាប់ ធ្វើបាបជាតិសាសន៍ឯងយ៉ាងឃោរឃៅ បំផ្លាញប្រទេសជាតិឯងលើគ្រប់វិស័យ មានសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ បំផ្លាញបញ្ញាស្មារតី ចំណេះវិជ្ជា សីលធម៌ ទ្រព្យសម្បត្តិ ជំនឿសាសនា មនោសញ្ចេតនាគ្រួសារ និងភាពសុខសាន្តរបស់ប្រជាជននិងប្រទេសជាតិខ្លួន ។

## នេះមកពីអ្វី?

មកពីរៀនចេះដឹងខាងផ្លូវលោក ប៉ុន្តែពុំបានសិក្សាខាងធម៌ដើម្បីដើរឲ្យបានទន្ទឹមគ្នារវាងពុទ្ធចក្រនិងអាណាចក្រទាំងពីរនេះមិនអាចកាត់ឲ្យដាច់គ្នាបានដែលជាឧបការៈឲ្យគ្នាឈានទៅរកភាពសុខសាន្តនិងរីកចម្រើនដ៏ក្រៃលែង ទាំងខាងស្មារតីនិងសម្ភារៈ ។ បុគ្គលសាបព្រោះពូជណានឹងច្រូតកាត់ទទួលផលនៃពូជនោះវិញ ។ ការប្រកែកគ្នាដោយពាក្យសម្ដីអាចធ្វើទៅបាន ប៉ុន្តែការប្រកែកនឹងសច្ចធម៌និងការពិតដែលបានប្រព្រឹត្តខ្លួនឯងដឹងដោយចិត្តខ្លួនឯង នោះមិនអាចធ្វើទៅបានទេ ដែលជាសាក្សីនៃខ្លួនឯងដោយពិត ។ មិនថាតែពួក ប៉ុល ពត ទេ ប៉ុន្តែអ្នកទាំងឡាយណាដែលធ្វើអំពើអាក្រក់ កាប់សម្លាប់មនុស្សដោយឥតមេត្តា ដឹកនាំប្រទេសទៅរកវិនាសកម្ម អ្នកនោះឯងនឹងពុំមានការគោរពស្រឡាញ់គាំទ្រទេ ។ នេះគឺដោយសារតែអ្នកនោះ ធ្វើឲ្យអ្នកដទៃព្រាត់ប្រាសនិងភ័យខ្លាច ដែលធ្វើឲ្យអ្នកផងទាំងឡាយពុំចង់ឃើញពុំចង់ជួបទៀតឡើយ ។ ហេតុនេះហើយបានជាព្រះសម្មាសម្ពុទ្ធ ទ្រង់សម្ដែងឲ្យវៀរចាក ជម្រះចិត្តឲ្យស្អាត ប្រាសចាកពីអំពើបាបនេះដែលនាំឲ្យមានទុក្ខទោសទាំងក្នុងលោកនេះនិង





លោកខាងមុខ ។

## ការដុសខាត់ជម្រះចិត្តដោយធម៌

ការដុសលាងជម្រះចិត្ត មិនត្រូវការទឹកសាប៊ូទេ ព្រោះចិត្តឥតមានរូបរាងឡើយ ។ បើរូបរាងកាយវិញ យើងនេះអាចដុសលាងដោយទឹកនិងសាប៊ូបាន ចំណែកចិត្តដែលប្រឡាក់ដោយអកុសលធម៌និងកិលេសធម៌ទាំងឡាយនោះ មានតែកុសលធម៌ទេ ទើបអាចដុសខាត់ចិត្តដែលឥតរូបរាងនេះបាន ។ កុសលធម៌ដុសសម្អាតចិត្តអកុសល កាលបើចិត្តខឹងក្រោធកើតឡើងត្រូវយកធម៌ខន្តី សេចក្ដីអត់ធន់និងចិត្តមេត្តាអនុគ្រោះមករំលត់ភ្លើងទោសៈនោះ ។ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ដឹងច្បាស់ណាស់ថាកិលេសធម៌ដែលធ្វើឲ្យចិត្តមនុស្សលោកសៅហ្មងមានច្រើនណាស់ មានកម្លាំងមិនងាយលះ ទើបទ្រង់ត្រាស់សម្ដែងធម៌សម្រាប់កម្ចាត់កិលេសក៏មានច្រើន ។

សរុបសេចក្ដីមក ព្រះសម្មាសម្ពុទ្ធគ្រប់ព្រះអង្គទ្រង់ផ្ដល់នូវឱវាទឲ្យវៀរចាក មិនធ្វើអំពើទាំងឡាយតាមផ្លូវកាយវាចាចិត្ត “ព្រះអង្គឲ្យបំពេញបុណ្យកុសលទាំងឡាយគឺកាយសុចរិត វចីសុចរិត មនោសុចរិតដោយទូន្មានខ្លួន អប់រំចិត្តក្នុងកុសលធម៌ ទាន សីល បញ្ញា ធ្វើឲ្យអកុសលធម៌វិនាសសាបសូន្យ” ព្រះអង្គឲ្យជម្រះចិត្តឲ្យស្អាតផូរផង់ ប្រាសចាកគ្រឿងសៅហ្មង ពោលគឺសម្អាតចិត្តស្ងប់ រម្ងាប់នីវរណធម៌ ស្ងប់អកុសលធម៌ទាំងឡាយ ឧបការៈឲ្យបញ្ញាកាន់តែមុតថ្លា លះបង់នូវអាសវក្កិលេសពីសន្តានបានដល់ទីបរមសុខ ។ ពាក្យទូន្មានទាំងអស់ គឺទ្រង់សំដៅផ្ដល់នូវសេចក្ដីមេត្តាដល់មនុស្សទាំងឡាយដែលចង់បានសេចក្ដីសុខ ។ កាលបើបុគ្គលទាំងឡាយគោរពប្រព្រឹត្តតាមនេះ អ្នកនោះឯងនឹងបានរួចចាកផុតទុក្ខដូចសេចក្ដីប្រាថ្នា ។ កាលបើមានសេចក្ដីសុខក្នុងជាតិនេះ សេចក្ដីសុខសប្បាយ នឹងកើតមាននៅជាតិខាងមុខទាំងអស់គ្នា ។ ដូច្នេះហើយ ពិភពលោកទាំងមូលនឹងមិនមានភ័យដែលប្រាសចាកនូវសេចក្ដីអន្តរាយនានា ព្រោះពុំមានខ្មាំងសត្រូវតាមយាយី ។ បុគ្គលទាំងឡាយសាងតែអំពើល្អដែលតែងនាំសុខក្សេមក្សាន្ត ។

សូមឲ្យមានសន្តិភាពខាងក្នុងចិត្ត សន្តិភាពក្នុងសង្គមនិងសន្តិភាពពិភពលោក គឺមនុស្សគ្រប់រូបបំពេញហេតុនាំឲ្យបានសុខ គឺអំពើល្អទាំងអស់ លះបង់អំពើបាបទាំងអស់គ្នា រួចចាកផុតទុក្ខទាំងអស់គ្នាដោយរក្សាខ្លួនក្នុងកុសលធម៌ មានសីលសមាធិបញ្ញា ។ ទាំងអស់នេះជាសារប្រយោជន៍នៃព្រះពុទ្ធសាសនា ក្នុងការអភិវឌ្ឍមនុស្សនិងសង្គមឲ្យមានសេចក្ដីសុខចម្រើនរៀងទៅ ។ ជាពិសេសសម្រាប់ប្រទេសកម្ពុជាដែលនឹងត្រូវធ្វើដំណើរលើមាគ៌ាផ្សះផ្សាជាតិ ។

# ការព្យាបាលរបួសចាស់ និង ការផ្សះផ្សាជាតិឡើងវិញ

ឆាំង យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានចំណាយរយៈពេល៩ឆ្នាំចុងក្រោយនេះដើម្បីប្រមូលចងក្រងឯកសារដែលទាក់ទងទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩) ។ មិនដល់រយៈពេល៤ឆ្នាំផង របបនេះបានធ្វើឲ្យប្រជាជនកម្ពុជាបាត់បង់ជីវិតអស់ប្រមាណពីរលាននាក់ឬច្រើនជាងមួយភាគបួននៃចំនួនប្រជាជនកម្ពុជាសរុបនៅពេលនោះ ។

អស់រយៈពេលជាច្រើនឆ្នាំមកហើយ ប្រជាជនកម្ពុជាជាច្រើនមានការឈឺចាប់និងគុំកួនចំពោះខ្មែរក្រហម ក៏ប៉ុន្តែអ្វីដែលមានសារសំខាន់បំផុតនោះគឺខ្ញុំសង្ឃឹមថា នៅថ្ងៃណាមួយ អ្នកដែលបានធ្វើបាបមនុស្សជាទីស្រលាញ់របស់ខ្ញុំនិងប្រជាជនកម្ពុជារាប់លាននាក់នឹងត្រូវនាំខ្លួនមកកាត់ទោសចំពោះឧក្រិដ្ឋកម្មដែលអ្នកទាំងនោះបានប្រព្រឹត្ត ។

ចាប់តាំងពីឆ្នាំ១៩៩៥មក មជ្ឈមណ្ឌលឯកសារកម្ពុជាបានសហការធ្វើការងារជាមួយសមាជិកនៃសហគមន៍ជាតិនិងអន្តរជាតិ រាជរដ្ឋាភិបាលកម្ពុជាដើម្បីប្រមូលចងក្រងឯកសារដែលលាតត្រដាងអំពីការពិតនៃរបបកម្ពុជាប្រជាធិបតេយ្យ ។







គ្មានអ្វីអាចផ្លាស់ប្តូរទស្សនៈរបស់ប្រជាជនកម្ពុជាជាច្រើនដែលថាកម្ពុជាត្រូវការសាលាជំនុំជម្រះក្តីមួយដែលមានដំណើរការដ៏ត្រឹមត្រូវដើម្បីកាត់ទោសជនល្មើសដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះអ្វីដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ។ សាលាជំនុំជម្រះក្តីមួយនេះអាចចេញសេចក្តីថ្លែងការណ៍ដ៏មានសារសំខាន់មួយថាអ្វីដែលខ្មែរក្រហមបានធ្វើគឺមិនអាចអត់ឱនឲ្យបានទេ ។ សាលាជំនុំជម្រះក្តីនេះអាចសម្រេចដាក់ពន្ធនាគារឧក្រិដ្ឋជនដែលរកឃើញថាមានកំហុស ហើយថែមទាំងអាចជួយកសាងនីតិរដ្ឋនៅកម្ពុជាទៀតផង ។ ទាំងអស់នេះមានសារសំខាន់ខ្លាំងណាស់ ។ ក៏ប៉ុន្តែត្រឹមតែសាលាជំនុំជម្រះក្តីតែមួយមុខគឺមិនមែនជាដំណោះស្រាយទាំងស្រុងទេ ហើយក៏មិនអាចធ្វើឲ្យសះស្បើយស្នាមរបួសពីអតីតកាលទាំងស្រុងបានដែរ ។ យើងត្រូវការឲ្យមាននៅយន្តការមួយបន្តពីការកាត់សេចក្តីថែមទៀត ។

ឆ្លងកាត់រយៈពេលជាច្រើនឆ្នាំមក ក្រៅពីសាលាជំនុំជម្រះក្តី យើងបានមើលឃើញតម្រូវការចាំបាច់ផ្សេងទៀតរបស់ប្រជាជនដែលពិបាកនឹងកំណត់ឲ្យច្បាស់ ។ កាលណាយើងយល់ដឹងបានកាន់តែច្រើន យើងកាន់តែមើលឃើញថា ទណ្ឌកម្មតែមួយមុខចំពោះមេដឹកនាំរបបខ្មែរក្រហមគឺមិនមែនជាដំណោះស្រាយទេ ។ គ្មានទណ្ឌកម្មណាមួយចំពោះមេដឹកនាំរបបខ្មែរក្រហមអាចធ្វើឲ្យប្រជាជនកម្ពុជារាប់លាននាក់ដែលបានស្លាប់បាត់បង់ជីវិតទៅហើយនោះរស់ឡើងវិញឡើយ ហើយក៏គ្មានទណ្ឌកម្មណាមួយអាចប៉ះប៉ូវការឈឺចាប់របស់ប្រជាជននៅក្រោមរបបនោះបានដែរ ។ តើការសម្លាប់អតីតកម្មាភិបាលខ្មែរក្រហមពីរលាននាក់អាចប៉ះប៉ូវចំពោះទង្វើឃោរឃៅដែលអ្នកទាំងនោះបានប្រព្រឹត្តចំពោះប្រជាជនកម្ពុជាបានខ្លះដែរឬទេ? តើការសងសឹកបែបនេះអាចជួយឲ្យកម្ពុជាគេចផុតពីភាពខ្មៅងងឹតនៅអតីតកាលដែរឬទេ? តើទេវតាអាចប៉ះប៉ូវអ្វីដែលយើងបាត់បង់បានដែរឬទេ? តាមរយៈការសួរសំណួរបែបនេះធ្វើឲ្យខ្ញុំយល់ថា ដំណោះស្រាយគឺឋិតនៅលើការព្យាបាលរបួសចាស់និងការផ្សះផ្សាជាតិឡើងវិញ ។

នៅពេលដែលយើងនឹកគិតដល់ភាពជាមនុស្ស ការចែករំលែកបទពិសោធន៍ ការជួយគ្នាទៅវិញទៅមក និងការយល់ដឹងអំពីអតីតកាល ពិតជាអាចជួយបន្ធូរបន្ថយការឈឺចាប់របស់យើងបានខ្លះ ។ មិនថាជនរងគ្រោះឬជនដៃដល់ទេ គ្រប់ៗគ្នាជាមនុស្សដែលបានឆ្លងកាត់នូវបទពិសោធន៍និងមានតម្រូវការផ្សេងៗ ។ គ្រប់ៗគ្នាចាំបាច់ត្រូវតែចូលរួមនៅក្នុងដំណើរការផ្សះផ្សាជាតិនិងជួយអ្នកដទៃទៀតឲ្យយល់ដឹងអំពីសោកនាដកម្មដែលប្រទេសរបស់ខ្លួនបានជួបប្រទះ ហើយបន្ទាប់មកត្រូវតែពុះពារបន្តទៅមុខទៀតក្នុងការកសាងជីវិតនិងប្រទេសជាតិ ។




មជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងយល់នូវព្រះពុទ្ធដីកា "ពៀររំងាប់ដោយការមិនចងពៀរ"

ឌួង សុភារិទ្ធ

នៅក្នុងសង្គមខ្មែរ ការកំណត់យកព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋត្រូវបានអនុវត្តជាច្រើនជំនាន់ ។ បាវចនាជាតិកម្ពុជាចែងក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣របស់ព្រះរាជាណាចក្រកម្ពុជាគឺ "ជាតិ សាសនា ព្រះមហាក្សត្រ" ។ ក្នុងមាត្រា៤៣ វាក្យខ័ណ្ឌទី៣ ក៏បានចែងដែរថា "ព្រះពុទ្ធសាសនាគឺជាសាសនារបស់រដ្ឋ" ។ ដូច្នេះព្រះពុទ្ធសាសនាបានចាក់ឫសយ៉ាងជ្រៅនៅក្នុងទំនៀមទម្លាប់ប្រពៃណីខ្មែរជាយូរលង់ណាស់មកហើយ ។

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ សេរីភាពនៃការគោរពប្រតិបត្តិសាសនាត្រូវបានកាត់បន្ថយពីកម្រិតទាបបំផុតមកដល់កម្រិតសូន្យសុង ។ ប្រជាជនដែលបានឆ្លងកាត់របបនេះយល់យ៉ាងច្បាស់ថា ខ្មែរក្រហមបានធ្វើទុក្ខបុកម្នេញលើសាសនាក្នុងអំឡុងឆ្នាំ១៩៧៥ - ១៩៧៩ ។

"ការធ្វើទុកបុកម្នេញលើសាសនា"គឺជាបទឧក្រិដ្ឋមួយក្នុងចំណោមបទឧក្រិដ្ឋមួយចំនួនដែលស្ថិតក្នុងច្បាប់កាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ។ ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មទាំងឡាយដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យត្រូវបានឡាយព្រះហស្តលេខាដោយសម្តេចព្រះនរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាក្នុងខែសីហា ឆ្នាំ២០០១ ។ នៅក្នុងជំពូកទី១ បទប្បញ្ញត្តិទូទៅ មាត្រា១បានកំណត់ច្បាស់ថា "ច្បាប់នេះរៀបចំឡើងក្នុងគោលបំណងវិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យនិងជនទាំងឡាយណាដែលត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនិងការរំលោភយ៉ាងធ្ងន់ធ្ងរលើច្បាប់ព្រហ្មទណ្ឌកម្ពុជា រំលោភទៅលើច្បាប់និងទំនៀមទម្លាប់អន្តរជាតិ ហើយនិងរំលោភលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ មេសា ១៩៧៥ ដល់ថ្ងៃ៦ មករា ១៩៧៩» ។

ដោយសារមានជំនឿលើព្រះពុទ្ធសាសនាយ៉ាងមុតមាំ ប្រជាជនខ្មែរមួយចំនួនដែលនៅរស់នៅតាមស្រុកស្រែចម្ការ ពុំបានគិតគូរល្អិតល្អន់ពីទង្វើដែលខ្មែរក្រហមបានប្រព្រឹត្តនៅក្នុងឆ្នាំ១៩៧៥ - ១៩៧៩ ថាជាបទល្មើសកម្រិតអន្តរជាតិធ្ងន់ធ្ងរនោះឡើយ ។ មិនតែប៉ុណ្ណោះទៀតសោត ជនរងគ្រោះ





មួយចំនួនមិនចង់រំពុកឡើងវិញនូវអតីតកាលដ៏ខ្មៅងងឹតដែលគ្របដណ្តប់ដោយអំពើឃោរឃៅព្រៃផ្សៃរបស់មេដឹកនាំខ្មែរក្រហមឡើយ ហើយសុខចិត្តទទួលរងការឈឺចាប់និងរស់ជាតិល្វីងជូរចត់យ៉ាងស្ងាត់ស្ងៀមទៅវិញដោយសារតែការភ័យខ្លាច ។ លើសពីនេះទៅទៀត មីងមា លោកយាយ លោកតាខ្លះបានលើកយកទស្សនៈព្រះពុទ្ធសាសនា "ពៀររំងាប់ដោយការមិនចងពៀរ" ដាក់ក្នុងចិត្តហើយបង្វែរជីវិតចេញពីយុត្តិធម៌ទៅវិញ ។

ទន្ទឹមនឹងនេះ ក៏នៅតែមានអតីតខ្មែរក្រហមមួយចំនួនទៀតយល់ច្រឡំដែរថា ទង្វើរបស់ខ្មែរក្រហមដែលបានប្រព្រឹត្តចំពោះជនរងគ្រោះរបស់ខ្លួន មិនគួរត្រូវបានរំពុកឡើងវិញទេ ពីព្រោះវាគឺជារឿងអតីតកាលដែលកន្លងហួសជាយូរឆ្នាំមកហើយ ។ ខៀវ សំផន អតីតគណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យបាននិយាយនៅឯសន្និសីទសារព័ត៌មាន នៅខែធ្នូ ឆ្នាំ១៩៩៨ ជាភាសាអង់គ្លេសទាំងរដាក់រដុបថា "រឿងដែលកន្លងហួសទៅហើយ ឲ្យវាហួសទៅចុះ" ។

ប្រសិនបើយើងបណ្តោយឲ្យអតីតកាលនៃកម្មពៀររបស់ខ្មែរក្រហមកន្លងហួសទៅនោះបញ្ជាក់ថា វាមិនមែនជាទង្វើមួយនៃ "ពៀររំងាប់ដោយការមិនចងពៀរ" ទេ ពីព្រោះថា ប្រសិនបើយើងមិនស្រាយពៀររបស់ខ្មែរក្រហមចេញទេ ពៀរនេះក៏បេះតែមានតទៅទៀត ។



ពាក្យថា «ពៀរ» មានន័យថា «ចំណងចិត្តក្រោធដែលចងដោយព្យាបាទ បម្រុងនឹងសងសឹកវិញ, ចំណងចិត្តជាសត្រូវៈ ចងពៀរ, ស្រាយពៀរ, មនុស្សមានពៀរ» ។ ចំណែកឯពាក្យថា «ពៃរ៍» ក៏មានន័យដូចគ្នាទៅនិងពាក្យ«ពៀរ»ដែរ ។ ខ្មែរប្រើពាក្យនេះជាបរិវារស័ព្ទសម្រាប់និយាយផ្សំនឹងពាក្យ «ទោស» គឺថាៈ ទោសពៃរ៍ គឺទោសនឹងពៀរ ឬទោសជាពៀរ ។ ពាក្យក្លាយរបស់ពាក្យ«ពៃរ៍» គឺ «ពៃរី» មានន័យថា អ្នកមានពៀរ, អ្នកចងពៀរ, បច្ចាមិត្ត, សត្រូវ ។ ច្រើនប្រើក្នុងពាក្យកាព្យៈ «យោធាឥតរានឹងពៃរី ប្រយុទ្ធវក់វីយ៉ាងអង់អាច ធ្វើឲ្យសត្រូវបាក់ខ្ទបខ្ទាច ថយរត់ប្រសាចលែងងាកក្រោយ» ។

ក្នុងន័យព្រះពុទ្ធសាសនា «ពៀរត្រូវរំងាប់ដោយការមិនចងពៀរ» គឺសំដៅលើ «ការរួចចាកពៀរព្រោះស្រាយពៀរ» មានន័យថា កាលបើបានជាចងពៀររួចទៅហើយដែលបានរួចរំដោះចាកពៀរលែងមានតទៅទៀត ព្រោះស្រាយចំណងពៀរនោះឲ្យជ្រះស្រឡះចេញ បើមិនស្រាយចេញទេ ពៀរក៏ចេះតែមានតៗទៅទៀត ។ ដូចពាក្យកាព្យថា «ទីឃាវុកុមារមានវាចារណ៍ចៀសពៀរបាន ទើបមានសុខក្សេមក្សាន្ត បានសោយរាជ្យគ្រងរដ្ឋពីរ» ។ (រឿងទីឃាវុកុមារនិងព្រះបាទព្រហ្មទត្តក្នុងទីឃាវុកុមារ ជាតក ជាពុទ្ធភាសិត) ។

តាមពុទ្ធវចនាលោកថែងថា «ពៀររំងាប់ដោយការមិនចងពៀរ» ។ តើការដែលយើងនាំយកមេដឹកនាំខ្មែរក្រហមមកកាត់ទោស ចាត់ទុកជាការចងពៀរដែរឬទេ? ឆ្លើយនឹងសំណួរនេះ ព្រះមហាសុមេធាធិបតី ទេព វង្ស សម្តេចព្រះសង្ឃរាជគណៈមហានិកាយនៃកម្ពុជា បានមានសង្ឃដីកាថា វាអត់មានពៀរទេ ក៏ប៉ុន្តែបើពៀរតទៅទៀតនោះ អាបួនទោសងដប់នោះ ។ បើដល់កាត់ទោសនោះ វាចេះតែខុសទៅ វាចេះតែអួសទាញទាំងអាអ្នក ទាំងអស់គ្នាហ្នឹង បើមិនពៀរនឹង ប៉ុល ពត ចុះ ប៉ុល ពត ទៅយកឯណា បើ ប៉ុល ពត ងាប់បាត់ទៅហើយ ។

ថ្វីដ្បិតតែមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមមួយចំនួនដូចជា សុន សេន, ប៉ុល ពត និង កែវ ពក បានស្លាប់ទៅហើយក៏ពិតមែន ប៉ុន្តែនៅមានមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលនៅរស់មួយចំនួនទៀត ដូចជា ខៀវ សំផន, នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ជាដើម ត្រូវតែមានចំណែកក្នុងការទទួលខុសត្រូវចំពោះអ្វីដែលបានកើតឡើងក្នុងអំឡុងពេលនៃការគ្រប់គ្រងអំណាចរបស់របបកម្ពុជាប្រជាធិបតេយ្យ ។

អំពើរបស់មេដឹកនាំខ្មែរក្រហមដែលធ្វើឲ្យបាត់បង់ជីវិតប្រជាជនដ៏ច្រើនសន្ធឹកសន្ធាប់ហ្នឹង តើគួរតែត្រូវបានកាត់ទោស ឬក៏បណ្តោយទៅតាមកម្មពៀរ? ឆ្លើយនឹងសំណួរនេះ ព្រះមហាសុមេធាធិបតី ទេព វង្ស បានមានសង្ឃដីកាថា មិនមែនបណ្តោយតាមកម្មពៀរទេ ។ អ្វីត្រូវតែវិនិច្ឆ័យទាំងអស់ ក៏ប៉ុន្តែវិនិច្ឆ័យឲ្យមានយុត្តិធម៌ផង សូមឲ្យវិនិច្ឆ័យមានយុត្តិធម' តាមរយៈសាសនាផង ។...កុំឲ្យប្រកប





នូវការគំរាមកំហែង ការប្រមាថមើលងាយ មើលថោកតបត ក្រែងពៀរហ្នឹងវាតគ្នាតទៅទៀត ។

ចំណែកសម្តេចព្រះសុគន្ធាធិបតី ប៊ួរ គ្រី ព្រះសង្ឃរាជគណៈធម្មយុត្តិកនិកាយនៃព្រះរាជាណាចក្រកម្ពុជា បានមានសង្ឃដីកាថា រឿងតុលាការ រឿងកាត់ទោសខ្មែរក្រហមអីទាំងអស់ហ្នឹង អាត្មាក្នុងឋានៈជាអ្នកបួស ។ អ្នកបួស បើយោងទៅតាមព្រះពុទ្ធដីកាសម្តេចព្រះសម្មាសម្ពុទ្ធ ស្តេចទ្រង់មានព្រះទ័យមេត្តា ករុណា មុទិតា ឧបេក្ខា ។ គឺថាមិនចំពោះថាអ្នកហ្នឹងជាស្អីទេ គឺទ្រង់មានព្រះទ័យអីចឹង សូម្បីតែទេវទត្តដែលតាមធ្វើគុតព្រះពុទ្ធអង្គ ព្រះពុទ្ធអង្គក៏ស្តេចទ្រង់ព្រះពុទ្ធានុញ្ញាតឲ្យចូលគាល់ដែរ ។

សម្តេចព្រះសុគន្ធាធិបតី ប៊ួរ គ្រី បានមានសង្ឃដីកាបន្តទៀតថា បើយើងគិតទៅតាមរបៀបខ្មែរយើងតាំងពីបរមបុរាណមក លោកថា «កាត់ទឹកមិនដាច់ កាត់សាច់វាឈឺ» អាហ្នឹងក៏មួយ នៅក្នុងចំណោមពាក្យខ្មែរយើងដែលមានច្រើនមក ។ មួយទៀតគេថា «យល់ញាតិ ឃ្លាតច្បាប់» ។ អាហ្នឹងក៏មួយទៀតដែរ ។ អីចឹងសង្គមខ្មែរយើងយកមកប្រើទាំងអស់ ច្បាប់ក៏ប្រើ សាច់ញាតិក៏ប្រើ ប្រើទាំងពីរ ។

សុភាសិតខ្មែរទាំងពីរឃ្លា ពិតជាត្រឹមត្រូវណាស់ ។ «កាត់ទឹកមិនដាច់ កាត់សាច់វាឈឺ» ជារឿងមួយពិបាកខ្លាំងណាស់ ហើយជារឿងឈឺចាប់ទៀតផង ។ ក្នុងលោកយើងនេះ គ្មានអ្វីដែលថាមិនអាចដោះស្រាយបាននោះទេ ប៉ុន្តែគ្រាន់តែត្រូវការពេលវេលាយូរបន្តិចប៉ុណ្ណោះ ។ ដើម្បីធ្វើឲ្យសង្គមមួយមានការអភិវឌ្ឍនិងក្លាយទៅជានីតិរដ្ឋ យើងត្រូវពុះពារឧបសគ្គគ្រប់បែបយ៉ាង និងទ្រាំទ្រការឈឺចាប់មិនតិចឡើយ ។ ស៊ូទ្រាំការលំបាកនិងការឈឺចាប់មួយរយៈពេល ប្រសើជាងការបណ្តែតបណ្តោយឲ្យមានការលំបាកនិងការឈឺចាប់បន្តនាំមុខយើងជារៀងរហូត ។ «យល់ញាតិឃ្លាតច្បាប់» ក៏ជារឿងពិត មិនប្រកែកបានដែរនៅពេលដែលយើងចេះតែបន្តការយោគយល់គ្នា ការអធ្យាស្រ័យឲ្យគ្នាដោយគ្មានដែនកំណត់នោះ ។ ការប្រើមនោសញ្ចេតនាហួសហេតុក្នុងការលើកលែងទោសឲ្យគ្នាជាហេតុធ្វើឲ្យច្បាប់មានតួនាទីកាន់តែតិចតួចនៅក្នុងដំណើរការសង្គមដើម្បីឈានទៅរកនីតិរដ្ឋ ។

សម្តេចព្រះសុគន្ធាធិបតី ប៊ួរ គ្រី បានមានសង្ឃដីកាបញ្ជាក់ទៀតថា ពាក្យថា «អភ័យ» បានន័យថា គេយកមក គេអប់រំឲ្យកែចិត្ត កែគំនិតប្រព្រឹត្តទៅតាមផ្លូវល្អវិញ ដូចជាអង្គុលិមារ អីចឹងដែរ ព្រះពុទ្ធអង្គទៅបញ្ឈប់កុំឲ្យអង្គុលិមារហ្នឹងធ្វើការអាក្រក់ តែលោកយកមកអប់រំឲ្យបួស ហ្នឹងអប់រំមួយហើយ ។ តែយើងមិនមែនថា ឲ្យមកបួសអីចឹងទេ យើងអាចថាមកចូលអប់រំទៅតាមផ្លូវសង្គមដែលយើងត្រូវការ ដែលយើងនាំគ្នាជួយកសាងជាតិទៅតាមផ្លូវណាដែលល្អអីចឹងទៅ ។

នៅក្នុងឆ្នាំ១៩៩៤ រាជរដ្ឋាភិបាលកម្ពុជាបានចេញច្បាប់មួយដាក់ខ្មែរក្រហមឲ្យនៅក្រៅច្បាប់ ប៉ុន្តែបច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជាបានអនុញ្ញាតឲ្យចូលរួមរស់ក្នុងសង្គមជាតិកម្ពុជាវិញ ហើយ

មជ្ឈមណ្ឌលឯកសារកម្ពុជា

បានលើកលែងទោសដល់មេដឹកនាំខ្មែរក្រហមមួយចំនួន ដូចជាករណី អៀង សារី ជាដើមដែលត្រូវបានតុលាការបដិវត្តន៍ប្រជាជនកម្ពុជាកាត់ឲ្យជាប់ទោសពីបទប្រល័យពូជសាសន៍នៅឆ្នាំ១៩៧៩ ។ រីឯច្បាប់ដើម្បីកាត់ទោសខ្មែរក្រហម គឺជាការស្រាយ «ពៀរ» ដែលធ្វើឲ្យស្របទៅតាមព្រះពុទ្ធបណ្ដាំថា «ពៀរ រំងាប់ដោយការមិនចងពៀរ» ។

ទាក់ទិននឹងសំណួរសួរថាតើក្នុងរបបខ្មែរក្រហមរឿងរ៉ាវនៃការសម្លាប់មនុស្ស វាជារឿងផ្លូវលោក ឬផ្លូវធម៌? ឆ្លើយនឹងសំណួរនេះ ព្រះមហាសុមេធាធិបតី ទេព វង្ស ក៏បានមានសង្ឃដីកាថា នេះបើតាមលោកគាពិចារណាក៏មិនជ្រៅជ្រះ មិនដាច់ស្រេចដែរ ។ ហេតុម៉េចបានថាដូច្នោះ? មកអំពីសត្វជាអ្នកអាស្រ័យកម្ម ។ «កម្ម» បានន័យថាអំពើដែលធ្វើ ។...មិនដឹងជា ប៉ុល ពត គេចាប់ផ្ដើមធ្វើ ឬក៏ជាពួកមួយមកពីផលហេតុអ្វី ។ បើថា ប៉ុល ពត គេមិនចាប់ផ្ដើមធ្វើទេ អានេះពៀររបស់ពួកយើង ហ្នឹងវាមានពៀរពីអតីតមក ។ «សោចបុព្វេ ចកត្ត បុញ្ញកា» នេះ វាហុចឲ្យពីអតីតកាលមក «អតីតា ជាតបច្ចុប្បន្នា ធម្មា» នោះ ។

ក្នុងរឿងកម្មពៀរនេះ មានសំណួរចោទសួរថាតើមេដឹកនាំខ្មែរក្រហមសព្វថ្ងៃនេះ បានទទួលកម្ម







ដែលគេបានប្រព្រឹត្តហើយឬនៅ? ឆ្លើយនឹងសំនួរនេះ សម្ដេចព្រះសុគន្ធាធិបតី ប៊ួរ គ្រី មានសង្ឃដីកាថា ពិភពលោកគេស្អប់គាត់ គេដាក់ទោសគាត់ ទាំងអស់ហ្នឹងជាបាបកម្មរបស់គាត់ហើយឃើញទេ អាហ្នឹងគាត់បានទទួលរបស់គាត់ហើយ ។ សព្វថ្ងៃពិភពលោកមានអង្គការសហប្រជាជាតិជាដើម គេបេះតែទទូចដើម្បីនឹងកាត់ទោសដាក់ទោសគាត់ហ្នឹង អាហ្នឹងសុទ្ធតែបាបកម្មរបស់គាត់ហើយ ។

សម្ដេចព្រះសុគន្ធាធិបតី ប៊ួរ គ្រី មានសង្ឃដីកាបញ្ជាក់បន្ថែមថា ព្រះពុទ្ធជាម្ចាស់លោកថា យើងមានកម្មជារបស់ខ្លួន កើតមកមានកម្មមកជាមួយហើយ ។...បើអត់កម្មអត់កើតទេ កើតព្រោះកម្ម រស់នៅព្រោះកម្ម ស្លាប់ទៅក៏ព្រោះកម្ម ។

សម្ដេចព្រះសុគន្ធាធិបតី ប៊ួរ គ្រី មានសង្ឃដីកាបញ្ជាក់បន្ថែមទៀតថា ក្នុងព្រះពុទ្ធសាសនាមិនប្រើពាក្យថៃដន្យដាច់ខាត គឺសុទ្ធតែកម្មទាំងអស់ កម្មហ្នឹងនាំឲ្យទៅអ៊ីចឹង អំពើដែលយើងធ្វើហ្នឹង នាំយើងទៅអ៊ីចឹង ។...ប៉ុន្ដែមនុស្សយើង បើយើងមិនជឿកម្ម យើងរកការស្ងប់អត់ឃើញទេ ក្នុងជីវិតរស់ក្នុងគ្រួសារក៏អ៊ីចឹង រស់នៅក្នុងសង្គមក៏អ៊ីចឹង ។

គ្រប់ទង្វើរបស់ខ្មែរក្រហមដែលបានប្រព្រឹត្តប្រឆាំងនឹងជនរងគ្រោះរបស់ខ្លួនមិនអាចចាត់ទុកថាជាថៃដន្យបានឡើយ ។ វាសុទ្ធតែជាចេតនានៃកម្មដែលខ្មែរក្រហមបានសាងមកទាំងអស់ ។ ប្រសិនបើខ្មែរក្រហមមិនជឿថា នេះជាកម្មរបស់ខ្លួនទេ នោះខ្មែរក្រហមពិតជាមិនអាចរស់នៅក្នុងសង្គមបានឡើយ ។ វិធីល្អបំផុតដើម្បីឲ្យខ្មែរក្រហមអាចរួមរស់នៅក្នុងសង្គមបាន លែងមានកម្មពៀរតទៅទៀតនោះ គឺត្រូវតែស្រាយនូវចំណងកម្មពៀរទាំងអស់នោះឲ្យជ្រះស្រឡះតាមរយៈការដាក់ឲ្យទទួលខុសត្រូវចំពោះមុខច្បាប់ ដើម្បីយុត្តិធម៌ និងការអភិវឌ្ឍសង្គមជាតិកម្ពុជាឈានទៅរកនីតិរដ្ឋ ។

នៅក្នុងន័យព្រះពុទ្ធសាសនា ក៏ដូចក្នុងន័យច្បាប់ដែរ ពៀរនឹងតាមផ្ដន្ទាចំពោះអ្នកដែលប្រព្រឹត្តនូវអំពើបាប ។ ច្បាប់នឹងផ្ដន្ទាទោសចំពោះបុគ្គលដែលប្រព្រឹត្តខុសនឹងច្បាប់ ។ ផ្អែកតាមគោលការណ៍ទូទៅនៃច្បាប់ គឺបុគ្គលគ្រប់រូបមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ ។ បើច្បាប់ផ្ដល់យុតិធម៌ពិតប្រាកដ កម្មពៀរនឹងលែងកើតមានទៀតហើយ ។ ការនាំយកមេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហមមកវិនិច្ឆ័យទោស គឺជាទង្វើមួយបង្ហាញនូវ «ពៀររំងាប់ដោយការមិនចងពៀរ» ។ ហេតុនេះការនាំយកមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមមកកាត់ទោស ពុំមែនជាការចងកម្មចងពៀរនោះទេ ប៉ុន្ដែត្រូវធ្វើយ៉ាងណាដើម្បីធានាឲ្យមានយុត្តិធម៌មួយដែលមនុស្សទូទៅអាចទទួលយកបាន នោះទើបអាចចាត់ទុកថាជា «ពៀររំងាប់ដោយការមិនចងពៀរ» បាន ។ ទោះបីជាមានយល់ឃើញយ៉ាងណាក៏ដោយ សង្គមមានច្បាប់ហើយច្បាប់មានតួនាទីសំខាន់គឺស្វែងរកយុត្តិធម៌ជូនជនរងគ្រោះដែលត្រូវបានរំលោភនៅក្នុងច្បាប់នៃសង្គម ។

